# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១៦៣៧ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០០៣

## ប្រកាស

ស្តីពី

## ការកែសំរួលគំរូបញ្ជីគណនេយ្យ មាតិកាថវិកា និងមាតិកាគណនីឃុំ សង្កាត់

នេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ / នស /៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងប្រកាសលេខ ៣២៩ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០០២ ស្តីពីទំរង់ និងមាតិកាថវិកាឃុំ សង្កាត់
- យោងប្រកាសលេខ ២៥០ សហវ.ប្រក ចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ២០០២ ស្តីពីការបង្កើតប្រព័ន្ធគណនី នៃគណនេយ្យថវិកា ឃុំ សង្កាត់
- យោងប្រកាសណែនាំលេខ ៩៣៨ សហវ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០២ ស្តីពីប្រព័ន្ធទូទាត់ និងគណនេយ្យឃុំ សង្កាត់
- យោងតាមសំណើរបស់អនុគណៈកម្មការកិច្ចការហិរញ្ញវត្ថុ នៃគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។

## សំរេច

ប្រការ ១ : ត្រូវបានកែសំរួលរបាយការណ៍ស្តីពីចំណូល ចំណាយប្រចាំខែ គំរូតារាង (រត_០៥) របាយការណ៍ស្តីពីចំណូលចំណាយប្រចាំឆមាស និងប្រចាំឆ្នាំ គំរូតារាង (រត_០៦)និងសលាកប័ត្រតាមដានកិច្ចសន្យា គំរូតារាង(រត_១០) នៃបញ្ជីគណនេយ្យរបស់រតនាគារខេត្ត ក្រុង ដែលភ្ជាប់តាមប្រកាសលេខ ៩៣៨ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ

ឆ្នាំ២០០២ ស្តីពីប្រព័ន្ធទូទាត់ នៃគណនេយ្យឃុំ សង្កាត់ ដោយប្រើជំនួសនូវតំរូតារាងដូចបានភ្ជាប់តាមប្រកាសនេះដោយរក្សាលេខ និងឈ្មោះដដែល ។

ប្រការ ២ : មាតិកាថវិកា ប្រភេទចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន (លេខកូដ ៦៨) ត្រូវតាមដានមាតិកាលំអិត ។ ដោយឡែកចំណាយលើការងារសាងសង់ (លេខកូដ ៦៨.០២) ត្រូវធ្វើការតាមដានលំអិតបន្តតាមកិច្ចសន្យានីមួយៗ ។

ប្រការ ៣ : គណនីដើម ចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន (គណនីលេខ ៦៨) ត្រូវបំបែកចេញជាអនុគណនីដែលមានលេខសំគាល់ និងឈ្មោះដូចខាងក្រោម :

- អនុគណនី ៦៨.០១ : សំភារៈ
- អនុគណនី ៦៨.០២: ការសាងសង់/ការងារ
- អនុគណនី ៦៨.០៣ : ទ្យសំភារៈ
- អនុគណនី ៦៨.០៩ : ផ្សេងៗ

ដោយឡែកអនុគណនី ៦៨.០២ ត្រូវបំបែកជាអនុគណនីបន្តសំរាប់តាមដានប្រតិបត្តិការនៃកិច្ចសន្យានីមួយៗ ។

ប្រការ ៤ : គណនេយ្យករឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ត្រូវធ្វើការកត់ត្រាតាមដានការអនុវត្តន៍សកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ស្របទៅតាមការកំណត់ក្នុងប្រការ ២ និងប្រការ ៣ របស់ប្រកាសនេះ ។

ប្រការ ៥ : គណនេយ្យករឃុំ សង្កាត់ នៅរតនាគារខេត្ត ក្រុងត្រូវបញ្ជីកាប្រតិបត្តិការចំណាយដែលទាក់ទងទៅនឹងសកម្មភាពអភិវឌ្ឍន៍មូលដ្ឋាន ហើយឆ្លុះបញ្ចាំងជាលំអិតនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ប្រការ ៦ : មេឃុំ ចៅសង្កាត់ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន ប្រធានរតនាគារជាតិ និងគ្រប់ស្ថាប័ន អង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តន៍ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

<u>ចំលងជូន:</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
  "ដើម្បីជូនជ្រាប"
- គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា
- សាលាខេត្ត ក្រុង
- ដូចប្រការ៦
  "ដើម្បីអនុវត្ត"
- ឯកសារ

នេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

រដ្ឋមន្ត្រីស្តីទី

គ្រុក រ៉ាប៊ុន